# F5 ការអនុវត្តថវិការដ្ឋ

## ប្រចាំខែធ្នូ ឆ្នាំ២០២២

ក្នុងឆ្នាំ២០២២ ការប្រមូលចំណូលជាតិ សម្រេចបាន ២៤ ៥៣៦ ប៊ីលានរៀល ស្មើនឹង ១១០,៣១% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២២ ខណៈដែលការអនុវត្តចំណាយសរុបថ្នាក់ជាតិ សម្រេចបាន ២៤ ៧៧០ ប៊ីលានរៀល ស្មើនឹង ៧៩,៦៥% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២២៖

**ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២២**

ចំណូល
២២ ២៤៣,១០ ប៊ីលានរៀល

ចំណាយ
៣១ ០៩៩,២១ ប៊ីលានរៀល

### » ចំណូលថវិកាសរុប




ចំណូលសារពើពន្ធ
២២ ៤៨៧,៩៣
ប៊ីលានរៀល
១១១,១៨%

ចំណូលមិនមែនសារពើពន្ធ
២ ០០៨,៨៩
ប៊ីលានរៀល
១០៤,០៧%

ចំណូលមូលធន
៣៩,៥៨
ប៊ីលានរៀល
៤៦,១៦%

១១០,៣១%
ធៀបនឹងច្បាប់
ហិរញ្ញវត្ថុ ឆ្នាំ២០២២

ការអនុវត្តចំណូលក្នុងប្រទេសសរុបថ្នាក់ជាតិ សម្រេចបាន ២៤ ៥៣៦ ប៊ីលានរៀល ស្មើនឹង ១១០,៣១% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២២ កើនឡើង ១៩,៥៥% ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២១ ដែលក្នុងនោះ ចំណូលសារពើពន្ធ សម្រេចបាន ២២,៤៨៨ ប៊ីលានរៀល ស្មើនឹង ១១១,១៨% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២២ កើនឡើង ២១,៥៨% និងចំណូលមិនមែនសារពើពន្ធ សម្រេចបាន ២ ០០៩ ប៊ីលានរៀល ស្មើនឹង ១០៤,០៧% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២២ កើនឡើង ១,៩៥%។

### » ចំណាយថវិកាសរុប




ចំណាយចរន្ត
១៦ ៦៩៣,៥៤
ប៊ីលានរៀល
៨៧,៣៥%

- ចំណាយបៀវត្ស
- ការទិញ
- សេវាកម្ម
- បន្ទុកហិរញ្ញវត្ថុ
- អត្ថប្រយោជន៍សង្គម
- ឧបត្ថម្ភធន

ចំណាយមូលធន
៨ ០៧៦,៦៣
ប៊ីលានរៀល
៦៧,៣៨%

៧៩,៦៥%
ធៀបនឹងច្បាប់
ហិរញ្ញវត្ថុ ឆ្នាំ២០២២

ការអនុវត្តចំណាយសរុបថ្នាក់ជាតិ សម្រេចបាន ២៤ ៧៧០ ប៊ីលានរៀល ស្មើនឹង ៧៩,៦៥% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២២ ដែលក្នុងនោះ ចំណាយមូលធន សម្រេចបាន ៨ ០៧៧ ប៊ីលានរៀល ថយចុះ ២៨,៥៧% រីឯចំណាយចរន្តសម្រេចបាន ១៦ ៦៩៤ ប៊ីលានរៀល ថយចុះ ១៤,៣៧% បើធៀបនឹងរយៈពេលអនុវត្តដូចគ្នា ឆ្នាំ២០២១។ ជារួម ការអនុវត្តការចំណាយ គឺនៅបន្តរក្សានូវគោលការណ៍រឹតបន្តឹងចំណាយមិនចាំបាច់នានា និងវិភាជថវិកាសម្រាប់អនុវត្តឱ្យចំមុខសញ្ញាប្រកបដោយបុរេសកម្ម បន្តដោះស្រាយផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

> “ រាជរដ្ឋាភិបាល បន្តភាពប្រយ័ត្នប្រយែងខ្ពស់ក្នុងការគ្រប់គ្រង និងប្រើប្រាស់ហិរញ្ញប្បទានសរុបថ្នាក់ជាតិ ប្រកបដោយប្រសិទ្ធភាពបំផុត និងផ្តល់លទ្ធភាពគ្រប់គ្រាន់ ឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តថវិការដ្ឋ បានទាន់ពេលវេលា។ ជាក់ស្តែង ការអនុវត្តហិរញ្ញប្បទានពីបរទេសសរុបថ្នាក់ជាតិ សម្រេចបាន ៤ ៤៩៤ ប៊ីលានរៀល ស្មើនឹង ៦៥,៨៦% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ស្របពេលប្រាក់បញ្ញើរដ្ឋាភិបាល សរុបមាន ៧៩ ប៊ីលានរៀល។ ”